**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ៧ ខែធ្នូ ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Dec-2012, 13:38
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងបដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញម្នាក់បន្ថែមទៀតដើម្បីជួយក្នុងការកំណត់អំពីសម្បទារបស់គាត់**

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង ឆូ មន្នី
ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង
Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**
**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីការពារក្ដី ("មេធាវីការពារក្ដី") លោក អៀង សារី សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចរបស់ខ្លួនស្ដីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ("សេចក្ដីសម្រេច")[1] ដែលក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើដោយផ្ទាល់មាត់របស់មេធាវីការពារក្ដីសុំតែងតាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែមចំនួនមួយរូប និងបានចេញសេចក្ដីសម្រេចថា លោក អៀង សារី មានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ដោយហេតុថា សេចក្ដីសម្រេចនេះត្រូវបានធ្វើឡើង ដោយមិនបានផ្ដល់ឱកាសឱ្យមេធាវីការពារក្ដីបង្ហាញអំពីព័ត៌មាន និងទឡ្ហីករណ៍ចាំបាច់នានាឡើយ។ ការខកខានមិនពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចនេះ នឹងបណ្ដាលឱ្យមានភាពអយុត្តិធម៌យ៉ាងច្បាស់ក្រឡែត។

## I. សាវតារ

១. លោក អៀង សារី មានអាយុ ៨៧ ឆ្នាំ។ គាត់ខ្សោយកំលាំងកាយ និងមានប្រវត្តិថា គាត់មានបញ្ហាបេះដូង មានបញ្ហាប្រព័ន្ធទឹកនោម និងរលាកសន្លាក់ឆ្អឹង[2]។

២. កាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១២ លោក អៀង សារី បានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោយមានអាការៈអស់កម្លាំង និងល្ហិតល្ហៃយ៉ាងខ្លាំង[3]។ លោក អៀង សារី បន្តសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេលជាងពីរខែ រហូតដល់ពេលដែលគាត់ត្រូវបានបញ្ជូនត្រឡប់មកមន្ទីរឃុំឃាំង អ.វ.ត.ក វិញកាលពីថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២[4]។ ក្នុងអំឡុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងក្រោយពីនោះមក លោក អៀង សារី មានអាការៈវិលមុខ

---

[1] សេចក្ដីសម្រេចស្ដីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/9។

[2] *សូមមើល ឧទាហរណ៍ ដូចខាងលើ* កថាខណ្ឌ ១ ដល់ ២។

[3] សារអេឡិចត្រូនិករបស់ Claude Bouchard មន្ត្រីសម្របសម្រួលជាន់ខ្ពស់មន្ទីរឃុំឃាំង ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១២, ប្រតិចារឹក, ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/125.1, ទំព័រ ១២។

[4] ការបញ្ជូន អៀង សារី មកកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក សម្រាប់សវនាការ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ចុះថ្ងៃទី ៧ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E239/2។

ដង្កក់ ស្ពឹកដៃជើង ហើយគាត់មិនអាចដើរបាន ឬសូម្បីតែងើបអង្គុយ ឬងើបឈរ ដោយគ្មានជំនួយឡើយ[5]។

៣. កាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ក្នុងអំឡុងពេលលោក អៀង សារី សម្រាកព្យាបាលនៅមន្ទីរពេទ្យ លោកវេជ្ជបណ្ឌិត លឹម ស៊ីវុតថា និងលោកវេជ្ជបណ្ឌិត គី ប៊ូ សួ តំណាងគណៈអភិបាលត្រួតពិនិត្យសុខភាពជនជាប់ចោទនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅមន្ទីរឃុំឃាំង អ.វ.ត.ក ("វេជ្ជបណ្ឌិតព្យាបាល") មានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើបច្ចុប្បន្នភាពជូនអង្គជំនុំជម្រះសាលាដំបូង និងភាគី អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី[6]។ លោកវេជ្ជបណ្ឌិត លឹម ស៊ីវុតថា បានបញ្ជាក់ថា ការថតឆ្អឹងក (CT Scan) លោកអៀង សារី បានបង្ហាញថា គាត់មានរោគសញ្ញាចុះខ្សោយនៃខួរក្បាលផ្នែកខាងក្រោម (vertebrobasilar insufficiency syndrome)។ វាជាបញ្ហាសុខភាពដែលមិនមានឈាមគ្រប់គ្រាន់ហូរចូលក្នុងក្បាលបណ្ដាលឲ្យវិលមុខ អស់កម្លាំង និងមានអាការៈស្ពឹក[7]។ ក្រោយពីវេជ្ជបណ្ឌិតព្យាបាលបានបញ្ចប់សក្ខីកម្មរបស់ខ្លួន សហព្រះរាជអាជ្ញា ស្នើសុំតែងតាំងអ្នកជំនាញប្រសាទសាស្ត្រជាតិ និងអន្តរជាតិមួយរូប "ក្នុងលក្ខណៈបន្ទាន់បំផុត" ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី[8]។ មេធាវីការពារក្ដី បានយល់ស្របនឹងសំណើនេះ[9]។

៤. កាលពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ខ្លួននឹងផ្ញើប្រតិចារិកនៃសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ និងរបាយការណ៍វេជ្ជសាស្ត្ររបស់លោក អៀង សារី ជូនដល់លោកសាស្ត្រាចារ្យ A. John Campbell អ្នកជំនាញខាងជំងឺមនុស្សចាស់ដែល

---

[៥] *សូមមើល* របាយការណ៍វេជ្ជសាស្ត្រប្រចាំថ្ងៃរបស់ អៀង សារី ដែលបានបញ្ជូនពីមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត, (*ឧទាហរណ៍ ឯកសារ* E11/86.1); របាយការណ៍អ្នកជំនាញទាក់ទងនឹងលោក អៀង សារី ដែលត្រូវបានរៀបចំឡើងជាការឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E238), ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/4; ប្រតិចារឹក, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/125.1, ទំព័រ ១២, ទំព័រ ១៤, បន្ទាត់ ៦២ ដល់ ៦៣; ប្រតិចារឹក, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/142.1, ទំព័រ ៧៨, ១០៦។

[៦] ប្រតិចារឹក, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E1/125.1។

[៧] *ដូចខាងលើ,* ទំព័រ ១៩ ដល់ ២០, ទំព័រ ៤៨ ដល់ ៤៩។

[៨] *ដូចខាងលើ,* ទំព័រ ៧៤។

[៩] *ដូចខាងលើ,* ទំព័រ ៨៣។

បានពិនិត្យលោក អៀង សារី កន្លងមក ដើម្បី "ស្នើសុំយោបល់ពីលោកសាស្ត្រាចារ្យ Campbell ថាតើត្រូវធ្វើកោសល្យវិច្ឆ័យវេជ្ជសាស្ត្របន្ថែមលើផ្នែកណា ទាក់ទិននឹងជនជាប់ចោទ អៀង សារី ក្នុងករណីចាំបាច់" [10]។

៥. កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ បន្ទាប់ពីលោកសាស្ត្រាចារ្យ Campbell បានគូសបញ្ជាក់ថា គាត់ពិបាកជឿជាក់អំពីមូលហេតុនៃការប្រែប្រួលលើការធ្វើរោគវិនិច្ឆ័យរបស់ជនជាប់ចោទ អៀង សារី ចាប់តាំងពីពេលគាត់បានពិនិត្យជនជាប់ចោទជាលើកចុងក្រោយ អង្គជំនុំជម្រះបានចាត់តាំង លោកសាស្ត្រាចារ្យ Campbell ដើម្បី៖

ក) ពិនិត្យជនជាប់ចោទ អៀង សារី និងពិនិត្យមើលឡើងវិញរាល់ព័ត៌មានវេជ្ជសាស្ត្រថ្មីៗ និង តេស្តដែលបានធ្វើលើជនជាប់ចោទ ចាប់តាំងពីពេលដែលលោកសាស្ត្រាចារ្យ Campbell បានធ្វើ របាយការណ៍លើកចុងក្រោយ។

ខ) ធ្វើតេស្ត ឬបានធ្វើតេស្តណាមួយបន្ថែម ដែលគាត់យល់ឃើញថាជាការសមស្របដើម្បីជួយ ដល់ការធ្វើរោគវិនិច្ឆ័យ។

គ) ពិគ្រោះជាមួយបុគ្គលដែលមានគុណវុឌ្ឍិផ្សេងទៀត (ដូចជា វេជ្ជបណ្ឌិតជំនាញផ្នែកកាំរស្មី) ដែលអាចជួយបកស្រាយ ឬបញ្ជាក់គាំទ្រលើការសន្និដ្ឋានរបស់គាត់ស្តីពីលទ្ធផលនៃតេស្ត ឬវត្តមាន នៃតេស្តវេជ្ជសាស្ត្រក្នុងស្រុក ដែលគាត់យល់ឃើញថាមានភាពចាំបាច់សម្រាប់ការធ្វើរោគវិនិច្ឆ័យ ទៅលើស្ថានភាពសុខភាពនាពេលបច្ចុប្បន្នរបស់ អៀង សារី។

ឃ) ជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើពុំមានតេស្តវេជ្ជសាស្ត្របែបនេះនៅ ភ្នំពេញ និង/ឬ ថាតើមានមូលដ្ឋានវេជ្ជសាស្ត្រ ឬមូលដ្ឋានជំនាញបច្ចេកវិទ្យាគ្រប់គ្រាន់ ដើម្បីធ្វើ តេស្តទាំងនោះបានសមស្របដែរ ឬយ៉ាងណា។

ង) រាយការណ៍មកអង្គជំនុំជម្រះសាលាដំបូងថាតើតេស្តវេជ្ជសាស្ត្រ ដែលគាត់យល់ឃើញថា ចាំបាច់សម្រាប់បញ្ជាក់គាំទ្រអំពីការធ្វើរោគវិនិច្ឆ័យលើស្ថានភាពសុខភាពនាពេលបច្ចុប្បន្នរបស់ អៀង សារី គួរធ្វើនៅកន្លែងណា និងក្រោមលក្ខខណ្ឌអ្វីខ្លះ។

---

[១០] សេចក្តីណែនាំទៅភាគីក្រោយសវនាការ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E233, កថាខណ្ឌ ២។

ច) រាយការណ៍មកអង្គជំនុំជម្រះសាលាដំបូង អំពីយោបល់របស់អ្នកជំនាញស្តីពីស្ថានភាពនាពេលបច្ចុប្បន្ននៃសុខភាពរបស់ជនជាប់ចោទ អៀង សារី និងថាតើនៅពេលណាគាត់អាចចាកចេញពីមន្ទីរពេទ្យ។

ឆ) ជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងអំពីការកែប្រែណាមួយ ដែលអ្នកជំនាញនឹងណែនាំនៅក្នុងការថែទាំវេជ្ជសាស្ត្រសម្រាប់ជនជាប់ចោទ អៀង សារី[11]។

៦. កាលពីថ្ងៃទី ៥ និង ៦ លោកសាស្ត្រាចារ្យ Campbell បានពិនិត្យលោកអៀង សារី។ របាយការណ៍របស់លោកសាស្ត្រាចារ្យ Campbell ត្រូវបានផ្តល់ជូនភាគីនៅរសៀលថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ [12]។ ក្នុងរបាយការណ៍នោះ លោកសាស្ត្រាចារ្យ Campbell បានសន្និដ្ឋានថា លោក អៀង សារី ពុំមាន ជំងឺខ្វះឈាមទៅខួរក្បាល (vertebrobasilar insufficiency syndrome) ទេ ប៉ុន្តែគាត់មាន ជំងឺវិលមុខភ្លាមកម្រិតស្រាលដោយសារជំហរ ឬចលនា (benign paroxysmal positional vertigo) [13]។ លោកសាស្ត្រាចារ្យ Campbell បានគូសបញ្ជាក់ថា ការវិលមុខ ជារឿងធម្មតាចំពោះមនុស្សចាស់ និងយល់ឃើញថា លោក អៀង សារី មានសមត្ថភាពចូលរួមសវនាការដោយមានការកែប្រែបន្តិចបន្តួចចំពោះការថែទាំសុខភាពរបស់គាត់[14]។ បន្ទាប់ពីទទួលបានរបាយការណ៍របស់លោកសាស្ត្រាចារ្យ Campbell មេធាវីការពារក្តី បានទាក់ទងមន្ត្រីច្បាប់ជាន់ខ្ពស់ ដើម្បីស្នើសុំការអនុញ្ញាតផ្តល់របាយការណ៍លោកសាស្ត្រាចារ្យ Campbell ឲ្យអ្នកជំនាញវេជ្ជសាស្ត្រមួយរូប ដើម្បីជួយមេធាវីការពារក្តីក្នុងការរៀបចំសម្រាប់ការពិនិត្យរបស់លោកសាស្ត្រាចារ្យ Campbell[15]។

---

[11] ការតែងតាំងសាស្ត្រាចារ្យ John A. Campbell សម្រាប់ជនជាប់ចោទ អៀង សារី, ថ្ងៃទី ៨ តុលា ឆ្នាំ ២០១២, ឯកសារ E238។

[12] របាយការណ៍អ្នកជំនាញ ទាក់ទងនឹងលោក អៀង សារី ដែលត្រូវបានរៀបចំឡើង ជាការឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E238), ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/4។

[13] *ដូចខាងលើ,* ទំព័រ ៣ ដល់ ៥។

[14] *ដូចខាងលើ,* ទំព័រ ២ ដល់ ៦។

[15] *សូមមើល* សារអេឡិចត្រូនិករបស់មេធាវីការពារក្តី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង, "សំណើសុំចែករំលែករបាយការណ៍អ្នកជំនាញ ឯកសារ E238/4", ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។

៧. កាលពីថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានយល់ព្រមតាមសំណើរបស់មេធាវីការពារក្ដីស្នើសុំផ្ដល់របាយការណ៍របស់លោកសាស្ត្រាចារ្យ Campbell ឱ្យទៅអ្នកជំនាញវេជ្ជសាស្ត្រម្នាក់[16]។ ភ្លាមៗនោះ មេធាវីការពារក្ដីបានទាក់ទងលោកវេជ្ជបណ្ឌិត Harold Bursztajn អ្នកជំនាញសរសៃប្រសាទវិកលវិទ្យា[17] ដើម្បីបញ្ជាក់ថាតើគាត់អាចពិនិត្យមើលរបាយការណ៍របស់លោកសាស្ត្រាចារ្យ Campbell និងផ្ដល់ជំនួយក្នុងការរៀបចំសម្រាប់ការពិនិត្យមើលរបស់លោកសាស្ត្រាចារ្យ Campbell នៅថ្ងៃបន្ទាប់ដែរឬទេ[18]។ លោកវេជ្ជបណ្ឌិត Harold Bursztajn បានពិនិត្យមើលដោយត្រួសៗ (ដោយសារពេលវេលាមានកម្រិត និងការដាក់កំហិតផ្សេងៗ) [19]ទៅលើរបាយការណ៍ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់លោកសាស្ត្រាចារ្យ Campbell និងបានផ្ដល់ការវិភាគដោយសង្ខេប[20]។ លោកវេជ្ជបណ្ឌិត Bursztajn យល់ឃើញថាវិធីសាស្ត្ររបស់លោកសាស្ត្រាចារ្យ Campbell មិនអាចទទួលយកបាន និងបានគូសបញ្ជាក់ថាលោកសាស្ត្រាចារ្យ Campbell ៖

១. [ពុំបាន]ធ្វើតេស្ដ៍សមត្ថភាពជាក់លាក់មួយ ទាក់ទងនឹងសមត្ថភាពរបស់ជនជាប់ចោទក្នុងការជួយដល់មេធាវី ដូចជាការពិនិត្យអំពីការចងចាំជីវប្រវត្តិរបស់ជនជាប់ចោទជាដើម។

២. [ពុំបាន]ធ្វើការវាយតម្លៃជាលក្ខណៈប្រព័ន្ធអំពីសមត្ថភាពនៃការយកចិត្តទុកដាក់ ការផ្លង់អារម្មណ៍ ភាសា និងមុខងារប្រតិបត្តិរបស់ជនជាប់ចោទ ទាក់ទងនឹងភាពអំណត់របស់ជនជាប់ចោទចំពោះការហេវហត់អស់កម្លាំង និងការឈឺចុកចាប់ នៅពេលដែលសវនាការចេះតែបន្តធ្វើ និងនៅពេលភាពស្មុគស្មាញនៃព័ត៌មានចេះតែកើនឡើង។

---

១៦ *សូមមើល* សារអេឡិចត្រូនិកពី Roger Phillips មន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង "យោង ៖ សំណើសុំចែករំលែករបាយការណ៍អ្នកជំនាញ ឯកសារ E238/4", ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២។

១៧ វេជ្ជបណ្ឌិត Bursztajn អ្នកឯកទេសនៅសាលាបណ្ដុះបណ្ដាលវេជ្ជសាស្ត្រ Harvard លើផ្នែកចិត្តវិកលវិទ្យាបច្ចេកវិទ្យា និងមានបទពិសោធយ៉ាងច្រើនលើផ្នែកនេះ។ *សូមមើល ប្រវត្តិផ្ទាល់ខ្លួន*របស់វេជ្ជបណ្ឌិត Bursztajn, ឯកសារ E115.2.2។

១៨ *សូមមើល* ការឆ្លើយឆ្លងសារអេឡិចត្រូនិករវាងមេធាវីការពារក្ដី និងលោកវេជ្ជបណ្ឌិត Bursztajn, ឯកសារ E238/6.2។

១៩ *សូមមើល* ប្រតិចារឹក, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/142.1, ទំព័រ ៤៩; ប្រតិចារឹក, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/143.1, ទំព័រ ៨ ដែលសហមេធាវីការពារក្ដីអន្តរជាតិ Michael G. Karnavas បានកត់សម្គាល់ថា លិខិតរបស់វេជ្ជបណ្ឌិត Bursztajn ជូនមេធាវីការពារក្ដី មិនមែនជារបាយការណ៍អ្នកជំនាញទេ ពីព្រោះថាវេជ្ជបណ្ឌិត Bursztajn មិនបានផ្ដល់ឱ្យខ្លួននូវព័ត៌មានចាំបាច់ទាំងអស់ ឬផ្ដល់ឱ្យក្នុងពេលវេលាដែលត្រូវរៀបចំរបាយការណ៍អ្នកជំនាញលើផ្នែកវេជ្ជសាស្ត្រ។

២០ លិខិតរបស់វេជ្ជបណ្ឌិត Bursztajn ផ្ញើជូនមេធាវីការពារក្ដី, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E238/6។

៣. [បានបដិសេធទាំងស្រុង]អំពីផលរំខានដែលអាចមានពីការប្រើប្រាស់ឱសថ ដោយផ្អែកតាមការសន្និតដោយឯកឯង ដែលថាដោយសារឱសថដែលជនជាប់ចោទប្រើប្រាស់ ពុំមានការផ្លាស់ប្តូរទើបជាតិពុលដែលបញ្ចេញបន្តិចម្តងៗក្នុងកម្រិតតិច ប៉ុន្តែគួរឲ្យកត់សម្គាល់ តាមជាលិកាប្រសាទទាក់ទងនឹងការប្រើប្រាស់ឱសថ អាចត្រូវបណ្តេញចេញ ឬអាចត្រូវបានកត់សម្គាល់ឃើញដោយវេជ្ជបណ្ឌិតព្យាបាលជនជាប់ចោទ[21]។

៨. កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ លោកសាស្ត្រាចារ្យ Campbell បានផ្តល់សក្ខីកម្មក្នុងតុលាការ[22]។ សក្ខីកម្មរបស់គាត់មានភាពស៊ីសង្វាក់គ្នានឹងរបាយការណ៍ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់គាត់។ បន្ទាប់ពីសក្ខីកម្មរបស់លោកសាស្ត្រាចារ្យ Campbell បានបញ្ចប់ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងភាគីថា នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ភាគីត្រូវបានផ្តល់ឱកាសរយៈពេលខ្លីដើម្បីធ្វើការកត់សម្គាល់ និងធ្វើសេចក្តីសង្កេតពាក់ព័ន្ធនឹងរបាយការណ៍របស់លោកសាស្ត្រាចារ្យ Campbell [23]។ មិនមានការបញ្ជាក់ច្បាស់ដល់ភាគីថា សវនាការថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ នឹងត្រូវរៀបចំក្នុងគោលបំណងជាក់លាក់ដើម្បីធ្វើសវនាការលើបញ្ហាសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនការឡើយ។

៩. កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ មេធាវីការពារក្តី បានលើកសំណើផ្ទាល់មាត់ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង តែងតាំងអ្នកជំនាញបន្ថែមម្នាក់ពិនិត្យលោក អៀង សារី ដើម្បីវាយតម្លៃសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ[24]។ មេធាវីការពារក្តីបានគូសបញ្ជាក់ថា ខ្លួនមិនបានលើកឡើងនូវសារណាស្នើសុំឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី ឡើយ ហើយវាជាការ "ឆាប់រហ័សពេក[25]"ក្នុងការលើកឡើងនូវសារណាអំពីសម្បទារបស់លោក អៀង សារី។ នៅពេលលោកស្រីចៅក្រម ខាតរ៉ាយធ៍ (CARTWRIGHT) សួរសំណួរ មេធាវីការពារក្តីបានឆ្លើយថា បច្ចុប្បន្ននេះ លោក អៀង សារី ពុំមានកាយសម្បទាដើម្បីចូលរួមសវនាការទេ

---

[២១] *ដូចខាងលើ*។

[២២] ប្រតិចារឹក, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/142.1។

[២៣] *ដូចខាងលើ,* ទំព័រ ១៤០។

[២៤] ប្រតិចារឹក, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/143.1, ទំព័រ ៧ ដល់ ១១។

[២៥] *ដូចខាងលើ,* ទំព័រ ៥ ដល់ ៦ "លោកត្រូវតែចាំថា យើងដែលជាមេធាវីការពារក្តី លោកអៀង សារី មិនបានធ្វើសំណើណាមួយសុំឲ្យមានការបញ្ឈប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី ឡើយ" *ដូចខាងលើ,* ទំព័រ ៥។

ប៉ុន្តែសវនាការអាចបន្តទៅមុខបានជាមួយសាក្សីដែលលោក អៀង សារី បានបោះបង់សិទ្ធិមានវត្តមាននៅពេលសវនាការ ដោយសង្ឃឹមថាសុខភាពរបស់លោក អៀង សារី នឹងអាចប្រសើរឡើង[26]។ សហព្រះរាជអាជ្ញាបានស្នើឡើងថា សវនាការគួរបន្តទៅមុខដោយឲ្យលោក អៀងសារី ចូលរួមពីបន្ទប់រង់ចាំស្ថិតនៅក្រោមសាលសវនាការ ហើយបានស្នើឡើងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចលើសម្បទារបស់លោក អៀងសារី នៅពេលនេះ ជាជាងរង់ចាំរហូតដល់ពេលសុខភាពរបស់គាត់មានលក្ខណៈប្រសើរឡើង[27]។ សហព្រះរាជអាជ្ញាលើកឡើងថា មិនមានភាពចាំបាច់ក្នុងការតែងតាំងអ្នកជំនាញបន្ថែមទៀតឡើយ[28]។ ដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រការលើកឡើងរបស់សហព្រះរាជអាជ្ញា[29]។

១០. កាលពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ មេធាវីការពារក្តីបានផ្ញើលិខិតមួយជូនលោកវេជ្ជបណ្ឌិត Bursztajn ដែលតាមរយៈលិខិតនោះ មេធាវីការពារក្តីស្នើសុំឲ្យគាត់ជួយផ្តល់ជំនួយមួយចំនួនក្នុងនោះគឺ "មតិយោបល់[ណា] ដែលយើងគួរផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូង ក្នុងការគាំទ្រសារណារបស់យើងដើម្បីបង្ហាញថា ការតែងតាំងអ្នកជំនាញដូចរូបលោក មានភាពចាំបាច់ និងសមហេតុផលក្នុងកាលៈទេសៈនេះ" [30]។

១១. វេជ្ជបណ្ឌិត Bursztajn បានឆ្លើយតប[31] នៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១២។ តាមយោបល់របស់គាត់ក្នុងឋានៈជាអ្នកជំនាញដែលមានបទពិសោធន៍ទូលំទូលាយ និងពាក់ព័ន្ធជាពិសេសទៅនឹងបញ្ហាសម្បទា វេជ្ជបណ្ឌិត Bursztajn បានបញ្ជាក់ថា ការវាយតម្លៃជំនាញលើសម្បទារបស់លោក អៀង សារី អាចនឹងត្រូវប្រើពេលវេលាប្រហែលប្រាំថ្ងៃ ដោយពិចារណាទៅលើភាពស្មុគស្មាញនៃការវាយតម្លៃ និងបញ្ហាសំខាន់ៗនានា ដូចជាជម្ងឺល្អិតល្អៃ និងសភាពប្រែប្រួលនៃសតិបញ្ញា។

---

[២៦] *ដូចខាងលើ,* ទំព័រ ១១ ដល់ ១២។

[២៧] *ដូចខាងលើ,* ទំព័រ ២៥ ដល់ ៣០។

[២៨] *ដូចខាងលើ,* ទំព័រ ៣៦ ដល់ ៣៧។

[២៩] *ដូចខាងលើ,* ទំព័រ ៣៩ ដល់ ៤២។

[៣០] លិខិតរបស់មេធាវីការពារក្តី ផ្ញើជូនវេជ្ជបណ្ឌិត Bursztajn, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២, ដែលបានភ្ជាប់មកជាមួយជាឧបសម្ព័ន្ធ ក។

[៣១] លិខិតរបស់វេជ្ជបណ្ឌិត Bursztajn ជូនមេធាវីការពារក្តី ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១២ ដែលភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ ខ។

គាត់បានផ្តល់អានុសាសន៍ដូចខាងក្រោមនេះ៖

ក. ការសិក្សាពីដំណើរការនីតិវិធី ដើម្បីវាយតម្លៃថាតើលោក អៀង សារី អាចតាមដាននីតិវិធីបានល្អគ្រប់គ្រាន់ដែលអាចឲ្យគាត់អាចជួយមេធាវីបានឬទេ។

ខ. ការសង្កេតមើលគាត់នៅក្នុងសវនាការក្នុងរយៈពេលមួយសមស្រប។

គ. ការសង្កេតមើលការប្រាស្រ័យទាក់ទងរវាងមេធាវី និងកូនក្តី។

ឃ. ការសម្ភាសន៍ធ្វើកោសល្យវិច័យលើមុខងារចិត្តប្រសាទ។

ង. ការវិភាគរកឥរិយាបថក្លែងបន្លំ ឬការធ្វើពុធជាល្ងីល្ងើ និង

ច. ពិនិត្យ និងវិភាគឯកសាររបស់មន្ទីរពេទ្យ និងពន្ធនាគារ។

ជាពិសេស វេជ្ជបណ្ឌិត Bursztajn បានបញ្ជាក់ថា អ្នកជំនាញត្រូវតែ៖

ជាគ្រូពេទ្យចិត្តប្រសាទដែលមានការបណ្តុះបណ្តាលខាងកោសល្យវិច័យ និងសមត្ថភាពធ្វើការសង្កេតល្អិតល្អន់ ជាប្រព័ន្ធអំពីស្ថានភាពចិត្តប្រសាទនៃមុខងារសតិបញ្ញារបស់ជនជាប់ចោទ ក្នុងដំណើរការនីតិវិធីរយៈពេលវែង ដែលរួមទាំងការប្រាស្រ័យទាក់ទងរបស់ជនជាប់ចោទជាមួយមេធាវីរបស់គាត់។ ជាពិសេស អ្នកជំនាញដែលមានការបណ្តុះបណ្តាលត្រូវតែមានសមត្ថភាពក្នុងការ៖

១. ពិនិត្យស្ថានភាពសតិបញ្ញាដោយផ្តោតទៅលើសម្បទា ដែលទាក់ទងទៅនឹងសមត្ថភាពក្នុងការជួយមេធាវី ដែលរួមទាំង ជាឧទាហរណ៍ ការវាយតម្លៃលើប្រព័ន្ធចងចាំរឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់ផងដែរ។ ការពិនិត្យនេះតម្រូវឲ្យមានការយល់ដឹងពីសម្បទាតាមលក្ខណៈពិសេសនៃបរិបទ លក្ខណៈពិសេសនៃមុខងារ (មិនមែនជាការយល់ដឹងបែបទូទៅទេ)។

២. វាយតម្លៃជាប្រព័ន្ធអំពីកម្រិតនៃការយកចិត្តទុកដាក់ ការផ្តង់អារម្មណ៍ ការយល់ និងការនិយាយឆ្លើយឆ្លងជាភាសាតុលាការរបស់ជនជាប់ចោទ និងការសម្រេចចិត្តរបស់គាត់ក្នុងពេលដែលគាត់ស៊ូទ្រាំនឹងជម្ងឺល្អិតល្អៃ និងការឈឺចាប់ខ្លាំងក្នុងអំឡុងពេលសវនាការ និងព័ត៌មានដែលបានដេញដោលកាន់តែមានភាពស្មុគស្មាញខ្លាំង។

៣. វាយតម្លៃល្អិតល្អន់លើវប្បធម៌ ដោយពិចារណាលើប្រវត្តិវប្បធម៌របស់ជនជាប់ចោទធៀបទៅនឹងវប្បធម៌នៃការជំនុំជម្រះ។

៤. វិភាគអំពីឥរិយាបទក្លែងបន្លំ ការបំផ្លើស ឬការធ្វើពុតជាល្ងីល្ងើ (ជាប្រធានបទដែលវេជ្ជបណ្ឌិត Bursztajn បានបង្រៀនក្នុងសិក្ខាសាលា សម្រាប់ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក)។

៥. ពិនិត្យដោយប្រុងប្រយ័ត្នលើប្រវត្តិសុខភាព និងសុខភាពផ្លូវចិត្ត និងពិចារណាពីទំនាក់ទំនងរវាងការចុះខ្សោយសុខភាពរាងកាយ និងសុខភាពចិត្តប្រសាទ។

៦. ធ្វើការវាយតម្លៃសក្តានុពលនៃផលរំខានពីការប្រើឱសថ រកឲ្យឃើញថាតើវាធ្ងន់ធ្ងរខ្លាំង ឬកើតឡើងក្នុងរូបភាពសន្សឹមៗ ដែលធ្វើឲ្យប្រព័ន្ធប្រសាទមានបញ្ហាធ្ងន់ធ្ងរ។

៧. ពិចារណារាល់ប្រវត្តិនៃរបួសក្បាល (ក្នុងពេលថ្មីៗ ឬយូរមកហើយ) ឬសញ្ញាសំខាន់ៗនៃរោគសញ្ញាសរីរាង្គខួរក្បាល។

៨. ពិចារណាទិន្នន័យរួមទាំងឡាយដែលពាក់ព័ន្ធនឹងការវាយតម្លៃ។

៩. ធ្វើការវាយតម្លៃតាមសត្យានុមតិ ដោយមិនគិតពីការជំទាស់របស់សហព្រះរាជអាជ្ញា ឬមេធាវីការពារក្តី (ក្នុងករណីផ្សេង ការធ្វើបែបនេះត្រូវបានជំទាស់កាលពីមុនដោយភាគីទាំងសងខាង)[32]។

១២. នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួន ដោយសម្រេចថា លោក អៀង សារី មានសម្បទាចូលរួមការជំនុំជម្រះ និងបដិសេធចោលសំណើរបស់មេធាវីការពារក្តីសុំតែងតាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម។

## II. ច្បាប់ និងអង្គហេតុ

### ក. អង្គជំនុំជម្រះសាលាដំបូងមានអំណាចជាប់មកជាមួយក្នុងការពិចារណាឡើងវិញទៅលើសេចក្តីសម្រេច

១៣. អង្គជំនុំជម្រះសាលាដំបូងមានអំណាចជាប់មកជាមួយ ក្នុងការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន ហើយក៏បានទទួលស្គាល់អំណាចនេះតាមរយៈការចេញសេចក្តីសម្រេចនាពេល

៣២ ដូចខាងលើ។

មុនៗលើសំណើសុំឲ្យពិចារណាលើផ្នែកអង្គសេចក្តីឡើងវិញផងដែរ[៣៣]។ ស្រដៀងគ្នានេះដែរ អង្គបុរេជំនុំជម្រះបានសម្រេចថា "អង្គបុរេជំនុំជម្រះមានអំណាចជាប់មកជាមួយដើម្បីពិចារណាសេចក្តីសម្រេចដែលខ្លួនបានចេញកាលពីលើកមុនសារជាថ្មី *នៅពេលដែលមានកាលៈទេសៈប្រែប្រួល ឬនៅពេលសេចក្តីសម្រេចលើកមុនមានកំហុស ឬ បណ្តាលឲ្យមានភាពអយុត្តិធម៌* "[៣៤]។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ការផ្លាស់ប្តូរកាលៈទេសៈ*អាច* កើតឡើងនៅក្នុងករណីដែលឃើញមានអង្គហេតុ ឬទឡ្ហីករណ៍ថ្មីលេចឡើង[៣៥]។ អង្គបុរេជំនុំជម្រះមានយុត្តិសាស្ត្ររបស់សាលាក្តី ICTY ជាបទដ្ឋានណែនាំ ដែលបានកត់សម្គាល់ថា៖ "[អង្គ]ជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានសម្រេចថា អង្គជំនុំជម្រះ "*ជាដរាប* អាចពិចារណាសេចក្តីសម្រេចដែលខ្លួនបានចេញពីលើកមុនសារជាថ្មី មិនមែនដោយសារតែមានកាលៈទេសៈប្រែប្រួលប៉ុណ្ណោះនោះទេ តែក៏ដោយសារនៅពេលដែលខ្លួនយល់ឃើញថា សេចក្តីសម្រេចលើកមុនមានកំហុស ឬបណ្តាលឲ្យមានភាពអយុត្តិធម៌"[៣៦]។

១៤. សេចក្តីសន្និដ្ឋានត្រូវបានលើកឡើងនៅក្នុងនេះថា សេចក្តីសម្រេច *ត្រូវ* យកមកពិចារណាសារជាថ្មីឡើងវិញ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំមានព័ត៌មានចាំបាច់ទាំងអស់នៅមុនពេលខ្លួនឈានដល់ការចេញសេចក្តីសម្រេច និងពុំទាន់បានស្តាប់គ្រប់ទឡ្ហីករណ៍ពាក់ព័ន្ធទាំងអស់នៅឡើយ។

---

[៣៣] *សូមមើល ឧ.* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E124/7។

[៣៤] សេចក្តីសម្រេចលើសំណើសុំឲ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩ ឯកសារលេខ D164/4/9 កថាខណ្ឌ ១២ (គូសបញ្ជាក់បន្ថែម)។

[៣៥] *រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ ឌុច* ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០២) សេចក្តីសម្រេចលើពាក្យសុំការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនៅក្នុងសណ្ណុំរឿង "ឌុច" ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D99/3/41/7 កថាខណ្ឌ ៦។

[៣៦] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារលេខ C22/I/68 កថាខណ្ឌ ២៥ (គូសបញ្ជាក់បន្ថែម) *ដកស្រង់* រឿងក្តី រដ្ឋ*អាជ្ញា ទល់នឹង Galić*, IT-98-29-AR73 សេចក្តីសម្រេចលើពាក្យសុំរបស់ស្ថាប័នអយ្យការស្នើសុំការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០១ កថាខណ្ឌ ១៣ និងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mucić* និងជនផ្សេងទៀត សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការដាក់ទោស ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៣ កថាខណ្ឌ ៤៩។

ប្រសិនបើមិនយកមកធ្វើការពិចារណាឡើងវិញទេនោះ សេចក្តីសម្រេចនេះនឹងបណ្តាលឲ្យមានភាពអយុត្តិធម៌យ៉ាងច្បាស់ក្រឡែត។

**ខ. ការពិចារណាសារជាថ្មីនេះចំបាច់ត្រូវធ្វើឡើង ដោយហេតុថា សេចក្តីសម្រេចដែលបានចេញនេះ ពុំបានស្តាប់ទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីឲ្យបានគ្រប់ជ្រុងជ្រោយលើភាពចាំបាច់ត្រូវកោះហៅអ្នកជំនាញម្នាក់ ឬច្រើននាក់បន្ថែមទៀត និងលើសម្បទាក្នុងការចូលរួមសវនាការរបស់លោក អៀង សារី**

១៥. អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិ ក្នុងការចេញសេចក្តីសម្រេច*តាមគំនិតផ្តួចផ្តើមរបស់ (proprio motu)* ខ្លួនបាន ប៉ុន្តែ "ការដែលអង្គជំនុំជម្រះសាលាដំបូងអាចចេញសម្រេចទៅបាននោះ ពុំមែនធ្វើឲ្យខ្លួនក្នុងនាមជាស្ថាប័នតុលាការ រួចផុតពីកាតព្វកិច្ចក្នុងការស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីដែលសិទ្ធិរបស់ពួកគេត្រូវបានប៉ះពាល់ដោយសារសេចក្តីសម្រេចនេះឡើយ"[៣៧]។ ក្រុមមេធាវីការពារក្តីពុំទាន់បានបង្ហាញជំហរទាំងស្រុងរបស់ខ្លួន អំពីភាពចាំបាច់ក្នុងការកោះហៅអ្នកជំនាញម្នាក់ ឬច្រើននាក់បន្ថែម ឬអំពីសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការនៅឡើយទេ[៣៨] ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចនេះលឿនពេក[៣៩]។

១៦. នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់របាយការណ៍វេជ្ជសាស្ត្រថ្មីៗរបស់លោក អៀង សារី ក្រោយពីលោកបានចូលសម្រាកនៅមន្ទីរពេទ្យ ឲ្យទៅលោកសាស្ត្រាចារ្យ Campbell ដើម្បី "ស្នើសុំយោបល់ពីសាស្ត្រាចារ្យថាតើត្រូវធ្វើកោសល្យវិច្ច័យ

---

[៣៧] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Jelisić* IT-95-10-A សាលដីកា៖ ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ២៧។

[៣៨] ករណីនេះត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងកថាខណ្ឌ ២១ នៃសេចក្តីសម្រេច៖ "ក្រុមមេធាវីការពារក្តីលោក អៀង សារី ... ពុំបានផ្តល់មូលដ្ឋានណាមួយសម្រាប់អង្គជំនុំជម្រះយកមកធ្វើជាមូលដ្ឋានក្នុងការច្រានចោលមតិយោបល់របស់អ្នកជំនាញដែលបានផ្តល់ជូន [ដោយលោកសាស្ត្រាចារ្យ Campbell] ឲ្យបានសមហេតុសមផល និងមិនបានផ្តល់ហេតុផលរឹងមាំថាហេតុអ្វីបានជាអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការគួរតែត្រូវជំនួសវិញនៅក្នុងពេលនេះ"។

[៣៩] *សូមមើលខាងលើ* កថាខណ្ឌ ៥-៦, ៨, ១០ ដែលបញ្ជាក់ថា ក្រុមមេធាវីការពារក្តីពុំបានទទួលដំណឹងគ្រប់គ្រាន់អំពីភាពចាំបាច់នៅក្នុងការបង្ហាញទឡ្ហីករណ៍ដោយផ្ទាល់មាត់ឲ្យបានពេញលេញ ឬ ពុំបានទទួលឱកាសគ្រប់គ្រាន់ក្នុងការបង្ហាញទឡ្ហីករណ៍ដោយផ្ទាល់មាត់ ហើយកំពុងធ្វើការរៀបចំសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរសម្រាប់ការតែងតាំងអ្នកជំនាញបន្ថែម។

វេជ្ជសាស្ត្របន្ថែមដែរឬយ៉ាងណា ទាក់ទិននឹងជនជាប់ចោទ អៀង សារី ក្នុងករណីចាំបាច់”[៤០]។ នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យលោកសាស្ត្រាចារ្យ Campbell ពិនិត្យកោសល្យវិច្ឆ័យ អៀង សារី បន្ទាប់ពីលោកសាស្ត្រាចារ្យ Campbell បានលើកឡើងថា លោកមិនអាចកំណត់ដោយពុំធ្វើការពិនិត្យកោសល្យវិច្ឆ័យលោក អៀង សារី ឡើងវិញបាននោះទេ[៤១]។ ការតែងតាំងលោកសាស្ត្រាចារ្យ Campbell ដោយអង្គជំនុំជម្រះសាលាដំបូង *ពុំមែន* ធ្វើឡើងក្នុងគោលបំណងតែងតាំងជាអ្នកជំនាញសម្រាប់កំណត់សម្បទាក្នុងការចូលរួមសវនាការនោះទេ។ លើសពីនេះ ការពិនិត្យកោសល្យវិច្ឆ័យរបស់លោកសាស្ត្រាចារ្យ Campbell ក៏*ពុំធ្វើឡើង* ក្នុងគោលបំណងសម្រាប់សវនាការលើបញ្ហាសម្បទានោះដែរ។ ក្រុមមេធាវីការពារក្ដីពុំបានដឹងអំពីភាពចាំបាច់ ឬពុំមានឱកាសរៀបចំសេចក្ដីសន្និដ្ឋានឲ្យបានពេញលេញលើបញ្ហាសម្បទានេះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានបំពេញកិច្ចដោយអយុត្តិធម៌ នៅពេលសម្រេចលើបញ្ហាសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ ដោយពុំបានស្ដាប់ទឡ្ហីករណ៍លើបញ្ហានេះពីក្រុមមេធាវីការពារក្ដីឲ្យបានពេញលេញ។

១៧. ក្រុមមេធាវីការពារក្ដីពុំបានយល់ថា វាមានភាពចាំបាច់ ឬវាគឺជាពេលវេលាសមល្មមនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ក្នុងការបង្ហាញទឡ្ហីករណ៍ស្ដីពីបញ្ហាសម្បទាក្នុងការចូលរួមសវនាការរបស់លោក អៀង សារី ទេ ដោយសារលោកបានបោះបង់សិទ្ធិមានវត្តមានក្នុងអំឡុងពេលស្ដាប់សក្ខីកម្មសាក្សីជាច្រើននាពេលខាងមុខនោះ[៤២]។ ដូចបានពន្យល់ជាច្រើនលើកជាច្រើនសាររួចមកហើយនៅអំឡុងពេលធ្វើសវនាការនាថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ការដាក់សេចក្ដីសន្និដ្ឋានលើបញ្ហាសម្បទានេះ គឺជាការធ្វើឡើងលឿនពេក ដោយហេតុថា “លោក អៀង សារី បានបោះបង់សិទ្ធិមានវត្តមាន [សម្រាប់]...សាក្សីទាំងអស់ដែលមាននៅក្នុងបញ្ជីសម្រាប់មក បង្ហាញខ្លួននៅក្នុង

---

[៤០] សេចក្ដីណែនាំទៅភាគីក្រោយសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E233 កថាខណ្ឌ ២។

[៤១] ការតែងតាំងសាស្ត្រាចារ្យ A. John CAMPBELL សម្រាប់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E238 កថាខណ្ឌ ១។

[៤២] ពាក្យសុំលះបង់សិទ្ធិមានវត្តមានមានដែនកំណត់ក្នុងកិច្ចដំណើរការសវនាការរបស់លោក អៀង សារី ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E229។ លិខិតលះបង់សិទ្ធិមានវត្តមានមានដែនកំណត់នៅអំឡុងពេលនៃកិច្ចដំណើរការសវនាការរបស់លោក អៀង សារី ចុះថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E237។ លិខិតលះបង់សិទ្ធិមានវត្តមានមានដែនកំណត់នៅអំឡុងពេលនៃកិច្ចដំណើរការសវនាការរបស់លោក អៀង សារី ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E237/1។

រយៈពេលដែលនៅសល់នៅក្នុងខែនេះ ហើយ...ប្រហែលជាសម្រាប់ខែ ធ្នូ ផង ដែរ... [ហេតុដូច្នេះ សម្បទា] របស់ជនជាប់ចោទ ពុំទាន់ដល់ពេលត្រូវយកមកធ្វើការពិភាក្សា ពីព្រោះថា កិច្ចដំណើរការនីតិវិធីអាចបន្តទៅមុខបានដោយគ្មានអ្វីមកអាក់ខានបានឡើយ"[៤៣]។ កិច្ចដំណើរការនីតិវិធីជាមួយនឹងសាក្សីដែលលោក អៀង សារី បានបោះបង់សិទ្ធិមានវត្តមាន នឹងផ្តល់ពេលវេលាសម្រាប់ធ្វើការវាយតម្លៃផ្នែកវេជ្ជសាស្ត្របន្ថែម និងសម្រាប់ការព្យាបាលឱ្យស្ថានភាពរបស់លោក អៀង សារី មានភាពធូរស្បើយឡើង។

១៨. ក្រុមមេធាវីការពារក្តីពុំបានបង្ហាញទឡ្ហីករណ៍ពាក់ព័ន្ធនឹងសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការនៅឡើយ រហូតទាល់តែមានការដាក់សម្ពាធពីចៅក្រម Cartwright ឱ្យដាក់ទឡ្ហីករណ៍ទាំងនេះ[៤៤]។ ដោយពិនិត្យលើរបាយការណ៍ពេទ្យ សក្ខីកម្មរបស់វេជ្ជបណ្ឌិតដែលបានព្យាបាល និងបានពិនិត្យលោក អៀង សារី និងរបៀប ព្រមទាំងវិសាលភាពនៃការពិនិត្យធ្វើកោសល្យវិច្ច័យរបស់វេជ្ជបណ្ឌិត Campbell ក្រុមមេធាវីការពារក្តីយល់ឃើញថា ការធ្វើកោសល្យវិច្ច័យបន្ថែមចាំបាច់ត្រូវធ្វើឡើងនៅមុនពេលសម្រេចពាក់ព័ន្ធនឹងសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ[៤៥]។

១៩. របាយការណ៍របស់លោកសាស្ត្រាចារ្យ Campbell មានព័ត៌មានបច្ចេកទេសខ្ពស់ខ្លាំង ដែលព័ត៌មានក្នុងនោះមួយចំនួន ស្ទើរតែពុំអាចឱ្យអ្នកដែលគ្មានសាវតារខាងផ្នែកវេជ្ជសាស្ត្រយល់បាន។ ម្យ៉ាងវិញទៀត ដោយពិចារណាលើការធ្វើរោគវិនិច្ឆ័យដោយវេជ្ជបណ្ឌិតព្យាបាលលោក អៀង សារី និងការសង្កេតផ្ទាល់ខ្លួនរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ភ្លាមៗមុនពេល និងចាប់តាំងពីលោកបានចូលសម្រាកក្នុងមន្ទីរពេទ្យ សេចក្តីសន្និដ្ឋានរបស់លោកវេជ្ជបណ្ឌិត Campbell គឺជាការគួរឱ្យភ្ញាក់ផ្អើលមួយ បើសិនជាមិនគួរឱ្យជឿនោះ។ ប្រសិនបើក្រុមមេធាវីការពារក្តីបានដឹងថា អង្គជំនុំជម្រះសាលាដំបូងមានបំណងបើកឱ្យសវនាការនាថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដើម្បីលើកឡើងអំពីបញ្ហាសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការក្នុងពេលបច្ចុប្បន្ន

[៤៣] ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E1/143.1 ទំព័រ ៦។ *សូមមើលផងដែរ* ទំព័រ ១២-១៤, ១៩។

[៤៤] *ដូចខាងលើ* ទំព័រ ១១៖ "លោក Karnavas អង្គជំនុំជម្រះមានសំនួរមួយចំនួនចង់សួរលោកក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក។ យើងពុំយល់ច្បាស់លាស់ថាតើលោកអះអាងថា លោក អៀង សារី បច្ចុប្បន្ន ពុំមានសម្បទា ឬ មានសម្បទា ឬ ថាតើលោក អៀង សារី ជាឧទាហរណ៍ អាចចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោមដែរឬយ៉ាងណា"។

[៤៥] *ដូចខាងលើ* ទំព័រ ៥-៨។

នោះ នោះក្រុមមេធាវីការពារក្តីបានស្នើសុំពេលវេលាបន្ថែមដើម្បីពិគ្រោះយោបល់ជាមួយអ្នកជំនាញ ដើម្បីត្រៀមរៀបចំឲ្យបានត្រឹមត្រូវសម្រាប់ធ្វើសេចក្តីសន្និដ្ឋានជាក់ជាមិនខាន។

២០. ក្រុមមេធាវីការពារក្តីបានដាក់សំណើដោយផ្ទាល់មាត់ សុំតែងតាំងអ្នកជំនាញវេជ្ជសាស្ត្រមួយរូបបន្ថែមទៀត កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២[៤៦]។ បន្ទាប់មក ក្រុមមេធាវីការពារក្តីបានចាប់ផ្តើមរៀបចំសំណើសុំជាលាយលក្ខណ៍អក្សរបន្ថែមមួយទៀតលើសំណើសុំនេះ ដើម្បីស្នើសុំតែងតាំងអ្នកជំនាញមួយរូបបន្ថែម ដែលសំណើបន្ថែមនេះនឹងត្រូវដាក់អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។ ដូច្នេះ ក្រុមមេធាវីការពារក្តីបានទាក់ទងវេជ្ជបណ្ឌិត Bursztajn ដើម្បីស្នើសុំមួយចំនួន *ក្នុងនោះ* បានស្នើសុំឲ្យលោកជួយផ្តល់ការណែនាំពាក់ព័ន្ធនឹងការតែងតាំងអ្នកជំនាញឯករាជ្យមួយរូប។

២១. នៅមុនពេលស្តាប់ទទ្បីករណ៍ទាំងអស់របស់ក្រុមមេធាវីការពារក្តី លើបញ្ហាសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ និងលើភាពចាំបាច់ត្រូវការអ្នកជំនាញបន្ថែមមួយរូបទៀត អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនមួយ។ វាជាការពុំសមហេតុផលមួយដែលអង្គជំនុំជម្រះសាលាដំបូង ៖ (១) បានតែងតាំងអ្នកជំនាញមួយរូបសម្រាប់ធ្វើកោសល្យវិច្ច័យលើគោលបំណងដូចបានលើកឡើងខាងលើ *ដែលមិនមែនជា* បញ្ហាសម្បទា (២) បានផ្តល់ឲ្យភាគីត្រឹមតែរយៈពេលមួយថ្ងៃពេញ ដើម្បីពិនិត្យរបាយការណ៍មួយដែលក្រោយមកត្រូវបានប្រើប្រាស់ដើម្បីសម្រេចលើបញ្ហាសម្បទា[៤៧] (៣) ពុំបានជូនដំណឹងដល់ភាគីឲ្យបានច្បាស់លាស់ថា សវនាការ និងការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ មានគោលបំណងពិតប្រាកដមួយដើម្បីលើកទទ្បីករណ៍អំពីបញ្ហាសម្បទា និង (៤) បន្ទាប់មក សម្រេចលើបញ្ហាសម្បទា ដោយពុំបានស្តាប់ភាគីនានាឲ្យបានពេញលេញ។ អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាសេចក្តីសម្រេចនេះសារជាថ្មី ដោយសារតែសេចក្តីសម្រេចនេះបានធ្វើឡើង ដោយពុំបានផ្តល់ឱកាសគ្រប់គ្រាន់ឲ្យក្រុមមេធាវីការពារក្តីធ្វើសន្និដ្ឋាន។

[៤៦] *ដូចខាងលើ* ទំព័រ ៧-១១។

[៤៧] *សូមមើលខាងលើ* សវតា កថាខណ្ឌ ៦-៨។

### គ. ការពិចារណាសារជាថ្មីនេះចំបាច់ត្រូវធ្វើឡើង ដោយហេតុថាសេចក្ដីសម្រេចលើបញ្ហាសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ ពុំអាចធ្វើឡើងដោយពុំស្ដាប់មតិយោបល់របស់អ្នកជំនាញបន្ថែមមួយរូប ឬ ច្រើនរូបនោះទេ

#### ១. ការធ្វើរោគវិនិច្ឆ័យរវាងគ្រូពេទ្យព្យាបាលលោក អៀង សារី និងសាស្ត្រាចារ្យ Campbell មានចំណុចពុំស៊ីសង្វាក់នឹងគ្នា

២២. ក្រោយពីបានពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញជាច្រើននាក់រួចមក[៤៨] ក្រោយពីបានទទួលខុសត្រូវលើការថែទាំលោក អៀង សារី អស់រយៈពេលមួយឆ្នាំ[៤៩] និងក្រោយពីបានថែទាំលោករយៈពេល ២៤ ម៉ោង ក្នុងមួយថ្ងៃ ខណៈពេលដែលលោកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ក្រុមគ្រូពេទ្យព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតមួយក្រុមបានរកឃើញថា លោក អៀង សារី ជួបបញ្ហា "ឈាមបញ្ចេញទៅក្បាលផ្នែកខាងលើរបស់លោកពុំគ្រប់គ្រាន់" ដែលបណ្ដាលឱ្យ "ចលនាបម្លាស់ទីមានកម្រិត"[៥០] និង "វិលមុខ"[៥១]។ ក្រុមគ្រូពេទ្យនេះបានរកឃើញថា "ឈាមពុំអាចបញ្ចេញទៅខួរក្បាល"[៥២] ហើយលោក អៀង សារី "អស់កម្លាំងល្ហិតល្ហៃនៅពេលដែល លោកត្រូវឆ្លើយនឹងសំណួរ...ដូច្នេះ យើងត្រូវកម្រិតពេលវេលាសម្រាប់ការស្ដាប់ចម្លើយ។ ខ្ញុំគិតថា មកទល់ពេលនេះ ពេលវេលាអតិបរិមាដែលយើងអាចស្ដាប់ចម្លើយលោក ប្រហែលជាអាចត្រឹម ១៥ នាទីប៉ុណ្ណោះ"[៥៣]។

២៣. ការវាយតម្លៃនេះគឺស្របគ្នានឹងការសង្កេតរបស់ក្រុមមេធាវីការពារក្ដីរបស់លោក អៀង សារី។ ក្រុមមេធាវីការពារក្ដីបានទាក់ទងយ៉ាងទៀងទាត់ជាមួយនឹងលោក អៀង សារី ក្នុងរយៈពេលជាងបួនឆ្នាំនេះ ហើយបានសង្កេតឃើញថាសុខភាពរបស់លោកបានថយចុះយ៉ាងខ្លាំង។ ក្នុងពេល

[៤៨] ប្រតិចារិក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E1/125.1 ទំព័រ ២០។

[៤៩] *ដូចខាងលើ* ទំព័រ ១១។

[៥០] *ដូចខាងលើ* ទំព័រ ១២។

[៥១] *ដូចខាងលើ* ទំព័រ ១៤។

[៥២] *ដូចខាងលើ* ទំព័រ ១៩។

[៥៣] *ដូចខាងលើ* ទំព័រ ៦២-៦៣។

បច្ចុប្បន្ន លោក អៀង សារី មានបញ្ហាដង្ហក់ខ្យល់ និងធ្វើឲ្យវិលមុខនៅពេលធ្វើចលនា[៥៤]។ លោក អៀង សារី មិនអាចផ្ចង់អារម្មណ៍បានទេ នៅពេលលោកមានអារម្មណ៍វិលមុខ[៥៥]។ លោក អៀង សារី ត្រូវទៅបត់ជើងតូចច្រើនដងក្នុងមួយម៉ោង ជាពិសេស នៅពេលព្រឹក[៥៦]។ ការចាំបាច់ត្រូវទៅបត់ជើងតូចញឹកញាប់នេះបានបណ្ដាលឲ្យមានការធ្វើចលនាជារឿយៗ ដែលជាហេតុធ្វើឲ្យលោកមានសភាពវិលមុខ ជាញឹកញាប់ ហើយករណីនេះបណ្ដាលឲ្យលោកបាត់បង់នូវលទ្ធភាពផ្ចង់អារម្មណ៍។ វាជា*ការយល់សាមញ្ញទៅហើយ* ថា បុគ្គលមួយរូបនៅក្នុងស្ថានភាពបែបនេះ មិនអាចចូលរួមនៅក្នុងការការពារក្ដីរបស់ខ្លួនប្រកដដោយអត្ថន័យពេញលេញបានឡើយ[៥៧]។

២៤. ផ្ទុយទាំងស្រុងពីការសន្និដ្ឋានរបស់គ្រូពេទ្យព្យាបាលលោក អៀង សារី និងការសង្កេតរបស់ក្រុមមេធាវីការពារក្ដី ក្រោយពីបានសង្កេត លោក អៀង សារី ក្នុងរយៈពេលខ្លីមួយរយៈមក លោកសាស្ត្រាចារ្យ Campbell បានសន្និដ្ឋានថា លោក អៀង សារី មានសម្បទាក្នុងការចូលរួមសវនាការ ដរាបណាបានអនុវត្តតាមអនុសាសន៍មួយចំនួនតូចជាក់លាក់ (ដូចជា ដាក់ប្រដាប់

---

[៥៤] ករណីនេះត្រូវបានទទួលស្គាល់ដោយលោកសាស្ត្រាចារ្យ Campbell។ *សូមមើល* របាយការណ៍អ្នកជំនាញស្ដីអំពីលោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238) ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E238/4 ទំព័រ ១។ ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E1/125.1 ទំព័រ ១៤, ២៦-២៧។

[៥៥] លោកសាស្ត្រាចារ្យ Campbell បញ្ជាក់ថា លោក អៀង សារី អាចផ្ចង់អារម្មណ៍នៅពេលលោកមានភាពស្រណុកសុខស្រួលផ្នែករាងកាយ និងនៅពេលពុំដង្ហក់ខ្យល់។ *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E1/142.1 ទំព័រ ២៥, ៥៣។

[៥៦] *សូមមើល ឧ.* របាយការណ៍សុខភាពរបស់លោក អៀង សារី ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E222/1 កថាខណ្ឌ ១៣។

[៥៧] អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នាពេលមុនថា វិធីសាស្ត្រសុភវិនិច្ឆ័យមួយគឺតម្រូវឲ្យសម្រេចអំពីសម្បទាក្នុងការចូលរួមសវនាការ៖ "ជនជាប់ចោទមានសម្បទាក្នុងការចូលរួមសវនាការ...នៅពេលដែលសមត្ថភាពរបស់គាត់ត្រូវបាន "ពិចារណាជាទូទៅ និងតាមសភាពសមហេតុសមផល និងដោយសុភវិនិច្ឆ័យ [ឃើញថា]មានកម្រិតមួយដែលអាចឲ្យ [គាត់]ចូលរួមក្នុងកិច្ចដំណើរការនីតិវិធី (ក្នុងករណីខ្លះ គាត់អាចចូលរួមបានទាល់តែមានជំនួយ) និងអាចអនុវត្តសិទ្ធិទាំងឡាយរបស់គាត់ដោយពេញលេញបាន"" សេចក្ដីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្ដីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E115/3 កថាខណ្ឌ ១៦។ "សេចក្ដីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ" ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E138 កថាខណ្ឌ ២៧ *ដកស្រង់* រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Strugar*, IT-01-42-A សាលដីកា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ៥៥។

ការពារទប់ក ជាដើម)[៥៨]។ អ្វីដែលគួរឱ្យងឿងឆ្ងល់នោះគឺថា លោកសាស្ត្រាចារ្យ Campbell បានធ្វើការ សន្និដ្ឋានដោយពុំបានព្យាយាមទៅនិយាយជាមួយវេជ្ជបណ្ឌិត លឹម ស៊ីវុតថា[៥៩] ដែលជាគ្រូពេទ្យព្យាបាលលោក អៀង សារី នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងដែលបានពិនិត្យលោក អៀង សារី ដោយផ្ទាល់ជារៀងរាល់ថ្ងៃក្នុងអំឡុងពេលលោក អៀង សារី ចូលសម្រាកក្នុងមន្ទីរពេទ្យ[៦០]។ លោកសាស្ត្រាចារ្យ Campbell ទំនងជាចង់ធ្វើការពិពណ៌នាអំពីសុខភាពរបស់លោក អៀង សារី ក្នុងរូបភាពឱ្យល្អមើលតែប៉ុណ្ណោះ។ ឧទាហរណ៍ របាយការណ៍របស់លោក Campbell បាន ហាក់បង្ហាញថា លោក អៀង សារី អាចក្រោកឈរឡើងបានដោយខ្លួនឯង[៦១] បើទោះជានៅពេលសាកសួរ លោកសាស្ត្រាចារ្យ Campbell បានទទួលស្គាល់ថា លោក អៀង សារី ពុំអាចសូម្បីតែក្រោកចេញពីគ្រែ ឬ អង្គុយបានដោយគ្មានគេជួយនោះ កុំថាឡើយដល់ក្រោកឈរឡើងនោះ[៦២]។

២៥. ក្នុងករណីដែលការវិនិច្ឆ័យរោគមានភាពពុំស៊ីសង្វាក់គ្នាដូច្នេះ ការស្តាប់មតិយោបល់របស់អ្នកជំនាញជាច្រើននាក់គឺជាបទដ្ឋានអនុវត្តមួយ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃសាលាក្តី ICTR បានកត់សម្គាល់ថា "[តាម]ការអនុវត្ត អង្គជំនុំជម្រះសាលាដំបូង ជាទូទៅ បានពិចារណាលើមតិយោបល់វិជ្ជាជីវៈនានា នៅមុនពេលចេញសេចក្តីសម្រេចតាមនីតិវិធីដ៏សំខាន់មួយបែបនេះលើបញ្ហាស្ថានភាពវេជ្ជសាស្ត្ររបស់ជនជាប់ចោទ ដែលអាចប៉ះពាល់ដល់កិច្ចដំណើរការជំនុំជម្រះក្តី"[៦៣]។ នៅក្នុងការសម្រេចលើសមត្ថភាពក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ Kovačević

---

[៥៨] *សូមមើល* របាយការណ៍អ្នកជំនាញស្តីអំពីលោក អៀង សារី ដែលត្រូវបានរៀបចំធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238) ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E238/4។

[៥៩] *ដូចខាងលើ* កថាខណ្ឌ ៤។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E1/142.1 ទំព័រ ៨៥-៨៦។

[៦០] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E1/125.1 ទំព័រ ៣៧។

[៦១] របាយការណ៍អ្នកជំនាញស្តីអំពីលោក អៀង សារី ដែលត្រូវបានរៀបចំធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណើ របស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238) ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E238/4 ទំព័រ ២, ៤។

[៦២] ប្រតិចារឹក ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E1/142.1 ទំព័រ ៧៤-៧៥។

[៦៣] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karamera និងជនផ្សេងទៀត* ICTR-98-44-AR73.16 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីករណី ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩ ដកស្រង់ ក្នុងនោះ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić* និង *Simatović* នៅសាលាក្តី ICTY ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងហោចណាស់លើ

នៅសាលាក្តី ICTY អង្គជំនុំជម្រះសាលាដំបូងបានពិចារណា និងប្រៀបធៀបរបាយការណ៍ជាច្រើនដែលត្រូវបានរៀបចំឡើងដោយអ្នកជំនាញដែលស្ថាប័នអយ្យការ ក្រុមមេធាវីការពារក្តី និង អង្គជំនុំជម្រះសាលាដំបូងខ្លួនឯង ជាអ្នកកោះហៅ នៅមុនពេលចេញសេចក្តីសម្រេច[៦៤]។ គ្រូពេទ្យព្យាបាលលោក អៀង សារី បានគូសបញ្ជាក់ម្តងហើយម្តងទៀតថា ដើម្បីកំណត់លើការព្យាបាលលោក អៀង សារី ឲ្យបានត្រឹមត្រូវ ការពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញជាច្រើនរូបបន្ថែម ដូចជា អ្នកជំនាញផ្នែកប្រសាទសាស្ត្រ អ្នកជំនាញផ្នែកវិទ្យុព្យាបាល និងអ្នកជំនាញផ្នែកបេះដូង ចាំបាច់ត្រូវធ្វើឡើង[៦៥]។ លោកសាស្ត្រាចារ្យ Campbell ខ្លួនឯងបានកត់សម្គាល់ថា ជាទូទៅ នៅក្នុងវិស័យវេជ្ជសាស្ត្រ ការផ្តល់មតិយោបល់ដោយអ្នកទីពីរ និងទីបី គឺជាបញ្ហាធម្មតា[៦៦]។

២៦. កាលពីមុនអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា "អង្គជំនុំជម្រះសាលាដំបូង អាចផ្អែកលើសេចក្តីសន្និដ្ឋាននៃការវាយតម្លៃរបស់អ្នកជំនាញតែមួយរូបក៏បាន នៅពេលអង្គជំនុំជម្រះសាលាដំបូងប្រមូលបានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើសេចក្តីសម្រេចរបស់ខ្លួន ក្រោយពីបានវាយតម្លៃរាល់កត្តាពាក់ព័ន្ធរួចហើយ"[67]។ មូលដ្ឋានបែបនេះមិនអាចយកមកអនុវត្តចំពោះករណីនេះបានទេ ពីព្រោះវេជ្ជបណ្ឌិតព្យាបាលលោក អៀង សារី និងសាស្ត្រាចារ្យ Campbell បានរកឃើញរោគវិនិច្ឆ័យពីរដែលខុសគ្នាយ៉ាងខ្លាំង។

---

របាយការណ៍វេជ្ជសាស្ត្រចំនួន ១១ ពីអ្នកជំនាញជាច្រើននាក់ដើម្បីសម្រេចលើសម្បទាក្នុងការចូលរួមសវនាការ។ នៅក្នុងរឿងក្តី *Karamera* អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ដោយសាររបាយការណ៍អ្នកជំនាញបានចុះហត្ថលេខាឯកភាពដោយវេជ្ជបណ្ឌិតជាច្រើននាក់ ដូច្នេះ វាពុំចាំបាច់តែងតាំងអ្នកជំនាញបន្ថែមឡើយ។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karamera និងជនផ្សេងទៀត* ICTR-98-44-T សេចក្តីសម្រេចលើការឃុំខ្លួនពាក់ព័ន្ធនឹងការបន្តការជំនុំជម្រះ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៩ កថាខណ្ឌ ១៧។

[៦៤] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kovačević*, IT-01-42/2-I សេចក្តីសម្រេចជាសាធារណៈលើសម្បទារបស់ជនជាប់ចោទក្នុងតតាំងទល់ក្តី ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦។ ទោះបីជានៅសាលាក្តី ICTY ភាគីអាចកោះហៅអ្នកជំនាញរបស់ខ្លួនបានហើយ នៅ អ.វ.ត.ក អងជំនុំជម្រះសាលាដំបូងជាអ្នកជ្រើសរើស និងតែងតាំងអ្នកជំនាញក៏ដោយ ក៏គោលការណ៍នេះគឺដូចតែគ្នា៖ អង្គជំនុំជម្រះគួរពិចារណាមតិយោបល់របស់អ្នកជំនាញមុនពេលធ្វើសេចក្តីសម្រេចឲ្យបានហ្មត់ចត់ដូចការពិចារណាលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ។

[៦៥] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E1/125.1 ទំព័រ ២០-២៣, ២៧-២៨, ៣៦-៤២, ៥៧, ៦៤។

[៦៦] ប្រតិចារឹក ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E1/142.1 ទំព័រ ៨៩-៩០។

[៦៧] សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមការជំនុំជម្រះ និងសំណើរបស់មេធាវីការពារក្តីសុំតែងតាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E115/3 កថាខណ្ឌ ១៨។

២៧. ដោយសារតែមានរោគវិនិច្ឆ័យពីរផ្ទុយគ្នាអំពីស្ថានភាពសុខភាពរបស់លោក អៀង សារី ការដែលអង្គជំនុំជម្រះសម្រេចទទួលយករបាយការណ៍របស់សាស្ត្រាចារ្យ Campbell ទាំងស្រុង និងបដិសេធចោលសេចក្តីសន្និដ្ឋានរបស់គ្រូពេទ្យព្យាបាលលោក អៀង សារី ដោយគ្មានមូលដ្ឋានវេជ្ជសាស្ត្រណាមួយក្នុងការកំណត់ថា រោគវិនិច្ឆ័យណាមួយមានភាពប្រៀបជាងនោះ មិនមែនជាការត្រឹមត្រូវទេ។ ការធ្វើបែបនេះបង្ហាញឲ្យឃើញថា អង្គជំនុំជម្រះបានជ្រើសរើសដោយមិនត្រឹមត្រូវនូវរបាយការណ៍ដែលមានទំនោរបំពេញទៅតាមការចង់បានរបស់សាធារណជន។ ការធ្វើបែបនេះក៏បង្ហាញឲ្យឃើញផងដែរថា អង្គជំនុំជម្រះជឿជាក់លើវេជ្ជបណ្ឌិតបស្ចិមប្រទេស ជាងវេជ្ជបណ្ឌិតខ្មែរដែលព្យាបាលគាត់ (ដែលយ៉ាងហោចណាស់ គួរត្រូវបានផ្តល់ឱកាសឲ្យឆ្លើយតបទៅនឹងការសន្និដ្ឋានរបស់សាស្ត្រាចារ្យ Campbell ដែលអះអាងថា រោគវិនិច្ឆ័យរបស់ពួកគាត់មានកំហុសឆ្គង និងឲ្យពួកគាត់ធ្វើការវិភាគលើរបាយការណ៍របស់សាស្ត្រាចារ្យ Campbell)។

២៨. ដើម្បីកំណត់ថា រោគវិនិច្ឆ័យណាមួយត្រឹមត្រូវ និងថាតើបច្ចុប្បន្ននេះ លោក អៀង សារី មានឬក៏គ្មានសម្បទាក្នុងការចូលរួមការជំនុំជម្រះ អង្គជំនុំជម្រះត្រូវតែតែងតាំងអ្នកជំនាញម្នាក់ ឬច្រើនបន្ថែម។ ក្នុងចំណោមបេសកកម្មរបស់ខ្លួន អ្នកជំនាញនេះត្រូវវាយតម្លៃជាប្រព័ន្ធលើកម្រិតនៃៈ (១) ការយកចិត្តទុកដាក់របស់លោក អៀង សារី (២) ការផ្តង់អារម្មណ៍របស់គាត់ (៣) លទ្ធភាពយល់ និងឆ្លើយឆ្លងរបស់គាត់ជាភាសាតុលាការ និង (៤) ការសម្រេចចិត្តរបស់គាត់ក្រោមការស៊ូទ្រាំនឹងជម្ងឺល្ហិតល្ហៃ និងការឈឺចាប់ខ្លាំង ក្នុងអំឡុងពេលសវនាការ និងព័ត៌មានដែលបង្ហាញជូនគាត់កាន់តែមានភាពស្មុគស្មាញខ្លាំង[68]។ អ្នកជំនាញត្រូវតែមានចំណេះដឹងពិសេសអំពីបញ្ហាសម្បទានៃការចូលរួមសវនាការ និងត្រូវតែមានបទពិសោធន៍ធ្វើការវាយតម្លៃបែបនេះ។ សាស្ត្រាចារ្យ Campbell ជាគ្រូពេទ្យជំនាញជម្ងឺមនុស្សចាស់ ប៉ុន្តែគាត់មិនមានសមត្ថភាពក្នុងការវាយតម្លៃនេះទេ[69]។

## ២. សាស្ត្រាចារ្យ Campbell មានកំហុសឆ្គងក្នុងការវិភាគអំពីសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ

[68] ចូរអានកថាខណ្ឌ ១១ ខាងលើ ដើម្បីមើលបញ្ជីតេស្តដែលវេជ្ជបណ្ឌិត Bursztajn ផ្តល់អនុសាសន៍ថាត្រូវតែធ្វើ។

[69] គុណវុឌ្ឍិរបស់សាស្ត្រាចារ្យ Campbell បង្ហាញថា មុនទទួលការតែងតាំងជាអ្នកជំនាញនៅ អ.វ.ត.ក គាត់បានធ្វើការវាយតម្លៃតែម្តងគត់ (ក្នុងអំឡុងពេលអាជីពរបស់គាត់ដ៏យូរ) ដើម្បីជួយតុលាការក្នុងការកំណត់សម្បទាចូលរួមការជំនុំជម្រះ។ ចូរអានឯកសារ E62.1។

២៩. សាស្ត្រាចារ្យ Campbell មានកំហុសឆ្គងក្នុងការពិចារណាពីស្ថានភាពរាងកាយ ដាច់ដោយឡែកពីស្ថានភាពសតិបញ្ញារបស់លោក អៀង សារី ដោយមិនបានពិចារណាពីស្ថានភាពរាងកាយខ្សោយដែលប៉ះពាល់ទៅលើសតិបញ្ញារបស់គាត់ឡើយ[70]។ កំហុសឆ្គងនេះស្តែងចេញពីការដែលសាស្ត្រាចារ្យ Campbell ពឹងផ្អែកទៅលើរបាយការណ៍ថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១២ ដែលគាត់បានរៀបចំជាមួយវេជ្ជបណ្ឌិត ហួត លីណា និងវេជ្ជបណ្ឌិត Seena Fazel ជារបាយការណ៍ដែលត្រូវបានរៀបចំ *មុនពេល* លោក អៀង សារី ចូលសម្រាកព្យាបាលពីរខែក្នុងមន្ទីរពេទ្យ ហេតុដូច្នេះរបាយការណ៍នេះលែងអាចជាមូលដ្ឋានសម្រាប់ការពិចារណាពីសម្បទារបស់លោក អៀង សារី តទៅទៀតហើយ។

៣០. របាយការណ៍ថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១២ ត្រូវបានបែងចែកជាផ្នែកដាច់ៗពីគ្នាសម្រាប់ "ការវាយតម្លៃលើសុខភាពរាងកាយ" និង "ការវាយតម្លៃលើសុខភាពផ្លូវចិត្ត ការចុះខ្សោយសតិបញ្ញា និងសម្បទាក្នុងការតតាំងក្តី និងចូលរួមការជំនុំជម្រះ"[71]។ ដើម្បីរៀបចំរបាយការណ៍នេះ តាមពិតពួកគាត់បានពិនិត្យលោក អៀង សារី (ប្រហែលមួយម៉ោងក្នុងថ្ងៃនីមួយៗ) ពីរថ្ងៃដាច់ដោយឡែកពីគ្នា ដែលមួយថ្ងៃទុកសម្រាប់ពិនិត្យសុខភាពរាងកាយ និងមួយថ្ងៃទៀតសម្រាប់ពិនិត្យសុខភាពផ្លូវចិត្ត[72]។ ដូចគ្នានឹងសាស្ត្រាចារ្យ Campbell ដែរ វេជ្ជបណ្ឌិត ហួត លីណា និងវេជ្ជបណ្ឌិត Seena Fazel មានកំហុសឆ្គងក្នុងការពិចារណាពីស្ថានភាពរាងកាយដាច់ដោយឡែកពីសុខភាពផ្លូវចិត្ត។ ដោយសារតែសុខភាពរាងកាយគាត់ខ្សោយ អ្វីដែលត្រូវការជាចាំបាច់ចំពោះស្ថានភាពលោក អៀង សារី គឺការវាយតម្លៃលម្អិតអំពីសម្បទា ដែលត្រូវពិចារណាពីផលប៉ះពាល់នៃសុខភាពរាង

---

[70] អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងមានកំហុស ដោយរកឃើញក្នុងសេចក្តីសម្រេចថា លោក អៀង សារី មិនមានការចុះខ្សោយសតិបញ្ញា ឬខាងផ្លូវចិត្ត ដែលអាចធ្វើឱ្យគាត់គ្មានសម្បទាចូលរួមក្នុងដំណើរការនីតិវិធី។ ចូរអានសេចក្តីសម្រេច កថាខណ្ឌ ២០, ២៦។

[71] ចូរមើលរបាយការណ៍សុខភាព អៀង សារី ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E222/1។

[72] ដូចកថាខណ្ឌ ៦, ២៧ របាយការណ៍នេះចង្អុលបង្ហាញថា វេជ្ជបណ្ឌិត ហួត លីណា ក៏បានជួបលោក អៀង សារី ក្នុងរយៈពេលខ្លី នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១២ នៅពេលដែលគាត់ជួយដល់វេជ្ជបណ្ឌិតរួមការងារក្នុងការសម្ភាសន៍ប្រពន្ធលោក អៀង សារី។ ចូរអានអ៊ីម៉ែលរបស់មន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង Roger Phillips ជូនមេធាវីការពារក្តី "ការពិនិត្យលោក អៀង សារី" ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១២ ដែលកត់សំគាល់ថាការសម្ភាសន៍នឹងចាប់ផ្តើមនៅម៉ោង ១ល្ងាច ហើយនឹងតម្រូវឱ្យលោក អៀង សារី អវត្តមានផ្នែកមួយនៃសវនាការស្តាប់សក្ខីកម្មដែលត្រូវចាប់ផ្តើមនៅម៉ោង ១.៣០នាទី និងសុំឱ្យបញ្ជាក់ថាតើលោក អៀង សារី លះបង់សិទ្ធិក្នុងការវត្តមានដែរឬទេ។

កាយទៅលើសម្បទាខាងផ្លូវចិត្ត និងស្ថានភាព *ក្រោយពីការសម្រាកព្យាបាលនៅមន្ទីរពេទ្យ*។

៣១. ការញែកដាច់ពីគ្នារវាងការពិចារណាលើសុខភាពរាងកាយ និងសុខភាពផ្លូវចិត្តរបស់លោក អៀង សារី បែបនេះ នាំឲ្យសាស្ត្រាចារ្យ Campbell សន្និដ្ឋានថា ដោយសារលោក អៀង សារី អនុវត្តបានគ្រប់គ្រាន់ក្នុងការធ្វើតេស្តពីសតិបញ្ញា (MMSE) សុខភាពផ្លូវចិត្តរបស់គាត់មិនបានកែប្រែ ហើយគាត់ពិតជាមានសម្បទាក្នុងការចូលរួមការជំនុំជម្រះ[73]។ គាត់បានសម្រេចបែបនេះ ដោយគ្មានអើពើពីផលវិបាកនៃសុខភាពរាងកាយលោក អៀង សារី ទៅលើលទ្ធភាពផ្តល់អារម្មណ៍ និងលទ្ធភាពណែនាំមេធាវីការពារក្តីរបស់គាត់ឡើយ[74]។ ប្រសិនបើលោក អៀង សារី មិនទម្រេតស្ងៀមឲ្យបានត្រឹមត្រូវក្នុងអំឡុងពេលសវនាការនីមួយៗទាំងអស់ទេ ដោយគាត់ងាកក្បាលបន្តិចបន្តួច ប្តូរជំហរ ឬក្រោកបត់ជើងតូច (ដោយមានជំនួយពីអ្នកដទៃដែរ) គាត់គ្មានលទ្ធភាពផ្តល់អារម្មណ៍ គ្មានលទ្ធភាពតាមដានដំណើរការនីតិវិធី ឬជួយក្នុងការការពារក្តីរបស់គាត់បានឡើយ[75]។

៣២. ដោយមិនបានសង្កត់ធ្ងន់ទៅលើសម្បទារបស់លោក អៀង សារី ក្នុងការផ្តល់អារម្មណ៍ និងតាមដានដំណើរការនីតិវិធីដើម្បីជួយក្នុងការការពារក្តីរបស់គាត់ សាស្ត្រាចារ្យ Campbell ហាក់ពិចារណាថា សម្បទាខាងសតិបញ្ញាមានលក្ខណៈដូចគ្នាទៅនឹងការគ្មានជម្ងឺផ្លូវចិត្ត ដូចជាជំងឺវង្វេងវង្វាន់ទេ។

---

៧៣ របាយការណ៍អ្នកជំនាញពាក់ព័ន្ធនឹងលោក អៀង សារី ដែលត្រូវបានរៀបចំឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (E238) ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E238/4 កឋាខណ្ឌ ១០។

៧៤ ក្នុងក្តី Strugar អង្គជំនុំជម្រះសាលាដំបូងបានសម្រេច (និងអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានតម្កល់) ថា ដើម្បីកំណត់សម្បទាក្នុងការចូលរួមការជំនុំជម្រះ តុលាការគប្បីវាយតម្លៃបញ្ហាវាយសម្បទារបស់ជនជាប់ចោទ ដែលមិនទាំងស្រុង ដូចខាងក្រោមនេះ៖

1. សម្បទាក្នុងការតតាំងក្តី។
2. សម្បទាក្នុងការយល់ពីលក្ខណៈនៃការចោទប្រកាន់។
3. សម្បទាក្នុងការយល់ពីដំណើរការនៃនីតិវិធី។
4. សម្បទាក្នុងការយល់ពីសេចក្តីលំអិតនៃភស្តុតាង។
5. សម្បទាក្នុងការណែនាំមេធាវីការពារក្តី។
6. សម្បទាក្នុងការយល់ពីផលវិបាកនៃដំណើរការនីវិធី និង
7. សម្បទាក្នុងការធ្វើសក្ខីកម្ម។

រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Strugar IT-01-42-T សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបញ្ចប់ដំណើរការនីតិវិធី ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៨ កឋាខណ្ឌ ៥៥។

៧៥ ដូចវេជ្ជបណ្ឌិតព្យាបាលលោក អៀង សារី បានទទួលស្គាល់ថាសូម្បីតែការធ្វើចលនាបន្តិចបន្តួចក៏ធ្វើឲ្យគាត់អស់កម្លាំងខ្លាំងដែរ។ ចូរអានប្រតិចារិក ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១២ ឯកសារ E1/125.1 ទំព័រ ២៧។

មិនដែលមានការអះអាងថា លោក អៀង សារី មានជំងឺផ្លូវចិត្តទេ។ និយាយដោយសាមញ្ញ នេះមិនមែនជាបញ្ហាទេ។

៣៣. ដូចគ្នានេះដែរ សាស្ត្រាចារ្យ Campbell មិនបានពិចារណាឲ្យបានត្រឹមត្រូវអំពីបរិបទដែលតម្រូវឲ្យលោក អៀង សារី ជួយមេធាវីការពារក្តីរបស់គាត់ឡើយ។ គាត់បានប្រដូចអលទ្ធភាពក្នុងការផ្តល់អារម្មណ៍ និងជួយក្នុងការការពារក្តីរបស់គាត់ក្នុងអំឡុងពេលជំនុំជម្រះ ដែលក្នុងនោះលោក អៀង សារី ប្រឈមមុខនឹងពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត ទៅនឹងការដេកលក់មួយស្របក់ក្នុងអំឡុងពេលស្តាប់បទបង្ហាញមួយ[76]។ និយាយដោយសាមញ្ញ សាស្ត្រាចារ្យ Campbell មិនយល់អំពីភាពស្មុគស្មាញដែលចោទជាបញ្ហា ឬសារៈសំខាន់នៃរឿងក្តីចំពោះលោក អៀង សារី ឡើយ។ ការដែលអង្គជំនុំជម្រះសាលាដំបូងទទួលយករបាយការណ៍របស់សាស្ត្រាចារ្យ Campbell ដោយមិនស្វែងរកការវាយតម្លៃដោយឯករាជ្យ គឺជាកំហុសឆ្គង និងជាភាពអយុត្តិធម៌។

## ៣. ត្រូវតែមានអ្នកជំនាញបន្ថែមជាចាំបាច់

៣៤. មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ស្វែងរកយោបល់ខាងវេជ្ជសាស្ត្រពីបុគ្គលផ្សេង ដូចជា វេជ្ជបណ្ឌិត Bursztajn ដែលមានបទពិសោធន៍ក្នុងការពិនិត្យសមត្ថភាពក្នុងការផ្តល់ជំនួយពីជនជាប់ចោទក្នុងការការពាររឿងក្តីរបស់ខ្លួន ដែលមានទំហំធំធេង និងមានភាពស្មុគស្មាញដូចជាសំណុំរឿង ០០២ នេះ។ វេជ្ជបណ្ឌិត Bursztajn គឺជាបុគ្គលដែលមានគុណវុឌ្ឍិខ្ពស់[77] ព្រមទាំងមានជំនាញ[78] និងបទពិសោធន៍[79]ដែលពាក់ព័ន្ធផ្ទាល់នឹងបញ្ហានេះ។ សាស្ត្រាចារ្យ Campbell មិនមានជំនាញបែបនេះទេ ហើយគាត់មិនដែលបានអនុវត្តតេស្តដ៏ចាំបាច់នេះឡើយ។

---

[៧៦] ប្រតិចារិក ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E1/142.1, ទំព័រ ៥៦។

[៧៧] ចូរអានប្រវត្តិរូបរបស់វេជ្ជបណ្ឌិត Harold Bursztajn ឯកសារ E115.2.2។

[៧៨] ឧទាហរណ៍ *ប្រវត្តិរូប* របស់វេជ្ជបណ្ឌិត Harold Bursztajn បានរាយឈ្មោះការវាយតម្លៃ/កោសល្យវិច័យខាងចិត្តប្រសាទនៃជនបាត់បង់សម្បទា និងជនគ្មានសមត្ថភាព ដែលជាមុខវិជ្ជាស្រាវជ្រាវចម្បង ហើយគាត់បានសរសេរអត្ថបទនានាអំពីប្រធានបទ ដូចជា "គោលការណ៍ណែនាំគ្លីនិកសំរាប់វាយតម្លៃ និងការបង្ហាញអំពីទម្រង់អ្នកជម្ងឺអសមត្ថភាពក្នុងស្ថាប័នច្បាប់"។ ដូចខាងលើ ទំព័រ ៥, ៧។

[៧៩] សូមមើលកថាខណ្ឌខាងលើ កថាខណ្ឌ ១១។

៣៥. មេធាវីការពារក្តីមិនដែលបានជួបវេជ្ជបណ្ឌិត Bursztajn ទេ។ មេធាវីការពារក្តីមិនដែលមានទំនាក់ទំនងអ្វីពីមុនជាមួយវេជ្ជបណ្ឌិត Bursztajn ឡើយ។ មេធាវីការពារក្តីបានប្រាស្រ័យទាក់ទងជាមួយវេជ្ជបណ្ឌិត Bursztajn ជាលើកទី១ នៅថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១២ ក្នុងគោលបំណងសុំឲ្យគាត់ជួយពិនិត្យមើលរបាយការណ៍របស់សាស្ត្រាចារ្យ Campbell ។ មេធាវីការពារក្តីសូមជម្រាបថា អ្នកជំនាញដែលមានគុណវុឌ្ឍិប្រហាក់ប្រហែល ក៏អាចទទួលយកបានដែរ ប៉ុន្តែអ្នកជំនាញនេះត្រូវតែជាបុគ្គលដែលគ្មានការពាក់ព័ន្ធនឹងការវាយតម្លៃសុខភាពរបស់លោក អៀង សារី កាលពីមុន[80]។ ការធ្វើបែបនេះនឹងកាត់បន្ថយការព្រួយបារម្ភថា សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ អាចនឹងរងឥទ្ធិពលនៃចេតនាក្នុងការផ្តល់សុពលភាពទៅលើរបាយការណ៍ពីមុនរបស់អ្នកជំនាញ ឬរបាយការណ៍របស់សហសេវិករបស់ខ្លួន។ កោសល្យវិច័យវេជ្ជសាស្ត្របន្ថែមនេះ គឺជាការចាំបាច់សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូង សម្រេចបានត្រឹមត្រូវលើសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមការជំនុំជម្រះ មានន័យថា លទ្ធភាពរបស់គាត់ក្នុងការចូលរួមទាំងស្រុងក្នុងដំណើរការនីតិវិធី។

## ឃ. ការពិចារណាឡើងវិញគឺជាការចាំបាច់ ដោយសារសេចក្តីសម្រេចនេះនឹងនាំឲ្យមានភាពអយុត្តិធម៌យ៉ាងច្បាស់

៣៦. សេចក្តីសម្រេចនេះមិនមែនជាសេចក្តីសម្រេចខាងរដ្ឋបាល ឬអំពីការរៀបចំសវនាការឡើយ។ វាជាសេចក្តីសម្រេចដែលប៉ះពាល់ដោយផ្ទាល់ទៅលើសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ លោក អៀង សារី មានសិទ្ធិមានវត្តមានក្នុងពេលជំនុំជម្រះ ដែលរដ្ឋធម្មនុញ្ញកម្ពុជា[81] ច្បាប់បង្កើត អ.វ.ត.ក[82] វិធានផ្ទៃក្នុង[83] និងកតិកាសញ្ញា

---

[៨០] នៅតុលាការ ICTR ក្នុងរឿងក្តី *Karamera* អង្គជំនុំជម្រះសាលាដំបូង "បានចម្រេចថារបាយការណ៍របស់ប្រធានមន្ត្រីសុខភាព និងរបាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រឯករាជ្យ *ដែលមិនបានចូលរួមពីមុនក្នុងរឿងក្តី* [គឺមាន] ភាពចាំបាច់ក្នុងការទទួលបានការវាយតម្លៃទាំងស្រុងអំពីស្ថានភាពសុខភាព [របស់ជនជាប់ចោទ]"។ រដ្ឋអាជ្ញា ទល់នឹង Karamera et al ICTR-98-44-T ដីកាសម្រេចលើការពិនិត្យសុខភាពរបស់ Matthieu Ngirumpstse ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៩ កឋាខណ្ឌ ៧។

[៨១] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនិងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ សិទ្ធិមានវត្តមានក្នុងការជំនុំជម្រះគឺជាសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ដោយមាត្រា ១៤(៣)(ឃ) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) ដែលកម្ពុជាជាភាគីហត្ថលេខី។

អន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ[84] បានធានាផ្តល់ជូនគាត់។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) បានសម្រេចថា សិទ្ធិក្នុងការមានវត្តមាន "គឺដើម្បីធានាវត្តមានរបស់ជនជាប់ចោទ *ដែលមានសមត្ថភាពក្នុងការជួយដល់តុលាការតាមរយៈការលើកឡើងនូវការការពារក្តីរបស់ខ្លួន*[85]។ ការជំនុំជម្រះជនជាប់ចោទដែលគ្មានសម្បទាជួយដល់ការការពាររឿងក្តីរបស់ខ្លួន គឺជាភាពអយុត្តិធម៌យ៉ាងច្បាស់ក្រឡែត។ លោក Schomburg ជាអតីតចៅក្រមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ (ICTY/ICTR) បានពន្យល់ថា "សហគមន៍អន្តរជាតិបានទទួលស្គាល់ថា ជនជាប់ចោទមិនត្រូវក្លាយជាកម្មវត្ថុរបរន្តតូចមួយនៃដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ"[86]។

៣៧. មេធាវីការពារក្តីសូមបញ្ជាក់ថា បច្ចុប្បន្ននេះលោក អៀង សារី គ្មានសម្បទាក្នុងការចូលរួមក្នុងដំណើរការនីតិវិធីទេ ពីព្រោះគាត់មិនអាចផ្តង់អារម្មណ៍បានលើសពី ១០-១៥ នាទីក្នុងមួយពេលៗ

---

[៨២] មាត្រា ៣៥(ថ្មី)(ឃ) នៃច្បាប់បង្កើត អ.វ.ត.ក ចែង (បញ្ជាក់បន្ថែម) ថា៖ "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា សមស្របតាមមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ... ឃ. ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ..."។

[៨៣] វិធាន ៨១(១) នៃវិធានផ្ទៃក្នុងចែងថា ៖ "ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ លើកលែងតែមានបញ្ញត្តិផ្សេងចែងក្នុងវិធាននេះ"។ ផ្នែកពាក់ព័ន្ធក្នុងវិធាន ៨១(៥) ចែងថា៖ "នៅពេលដែលមានមូលហេតុសុខភាព ឬមូលហេតុធ្ងន់ធ្ងរដទៃទៀត ជនជាប់ចោទ មិនអាចចូលរួមដោយផ្ទាល់ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែ រូបកាយនិងស្មារតីសមស្របអាចចូលរួមក្នុងដំណើរការនីតិវិធីបាន អង្គជំនុំជម្រះអាចបន្តនីតិវិធីដោយមិនមានវត្តមានរបស់ជនជាប់ចោទ ដោយមានការយល់ព្រមពីជនជាប់ចោទ ឬ នៅពេលដែលអវត្តមានរបស់ជនជាប់ចោទឈានដល់កម្រិតមួយ ដែលបណ្តាលឲ្យមានការពន្យាពេលយ៉ាងយូរ ហើយ នៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវ អង្គជំនុំជម្រះបង្គាប់ថា ការចូលរួមរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវតែធ្វើឡើងតាមមធ្យោបាយសោតទស្សន៍សមស្រប"។

[៨៤] មាត្រា ១៤(៣)(ឃ) នៃ ICCPR ចែងថា៖ "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួនជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖ ... (ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន... "។

[៨៥] សេចក្តីសម្រេចរឿងក្តី Strugar កថាខណ្ឌ ៣២ (បញ្ជាក់បន្ថែម)។

[៨៦] ជាគោលការណ៍ យោបល់ជំទាស់របស់ចៅក្រម Schomburg ស្តីពីសិទ្ធិការពារខ្លួនដោយខ្លួនឯង កថាខណ្ឌ ៣ ក្នុងរឿងក្តីរដ្ឋអាជ្ញា ទល់និង Krajišnik IT-00-39-A សេចក្តីសម្រេចលើសំណើរបស់ Momčilo Krajišnik សុំការពារក្តីដោយខ្លួនឯង និងសម្រេចលើបណ្តឹងរបស់មេធាវីសុំតែងតាំងមិត្តតុលាការចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៧ និងសម្រេចលើបណ្តឹងសុំរបស់រដ្ឋអាជ្ញា ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧។

ដោយសារគាត់វិលមុខ និងល្ងិតល្ងៃ។ ការពិនិត្យត្រឹមត្រូវ និងល្អិតល្អន់ពីអ្នកជំនាញបន្ថែមមួយរូប ឬច្រើន នឹងជួយឲ្យមានការវាយតម្លៃមួយដែលមានតុល្យភាព និងត្រឹមត្រូវ។ សេចក្តីសម្រេចថា លោក អៀង សារី មានសម្បទាក្នុងការតាមដានដំណើរការនីតិវិធី ក្នុងពេលដែលមេធាវីការពារក្តីមានភស្តុតាងបញ្ជាក់ផ្ទុយពីនេះ នាំឲ្យមានភាពអយុត្តិធម៌យ៉ាងច្បាស់ក្រឡែត។ សេចក្តីសម្រេចនេះត្រូវបានចេញមុនពេលសមស្រប ដោយគ្មានបើកសវនាការស្តាប់ទឡ្ហីករណ៍ទាំងស្រុងរបស់មេធាវីការពារក្តី ហើយសេចក្តីសម្រេចនេះនឹងបង្ខំឲ្យលោក អៀង សារី ចូលរួមការជំនុំជម្រះ ដែលគាត់មិនអាចចូលរួមដោយមានន័យបាន ដោយមានការបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## III. សំណើ

**អាស្រ័យហេតុនេះ** និងដោយមានមូលហេតុទាំងអស់ដូចបានលើកឡើងក្នុងសំណើនេះ មេធាវីការពារសូមគោរពស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖ ក) ពិចារណាសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ និង ខ) តែងតាំងអ្នកជំនាញបន្ថែមមួយរូប ឬច្រើន ដើម្បីជួយអង្គជំនុំជម្រះក្នុងការកំណត់ពីសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមការជំនុំជម្រះ។

សូមអង្គជំនុំជម្រះសាលាដំបូង មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

សហមេធាវីការពារក្តីលោក អៀង សារី

**អាង ឧត្តម** **Michael G. KARNAVAS**

បានចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១២